ព្រឹត្តិបត្រប្រចាំត្រីមាសទី៣

គាំទ្រសមាគម CWA គឺពង្រឹងវិស័យទឹកស្អាតនៅកម្ពុជា



សម្រាប់ ខែកក្កដា ដល់ ខែកញ្ញា ឆ្នាំ២០២៦

១. បច្ចុប្បន្នភាពអំពីសមាគម CWA

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា CWA ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារៈ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគម CWA បម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគម CWA អាចចូលរួមបាន។

សមាគម CWA បង្កើតឡើងក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយមានស្ថាបនិកចំនួន ២០ រូប និងត្រូវបានក្រសួងមហាផ្ទៃសម្រេចអនុញ្ញាតឱ្យចុះឈ្មោះក្នុងបញ្ជីសមាគម CWA តាមរយៈលិខិតលេខ ១០៧៧ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។


ដោយមានភាពរីកចម្រើន ទទួលបានទំនុកចិត្ត និងការគាំទ្រពីប្រតិបត្តិករ ក្រុមហ៊ុន សហគ្រាស និងស្ថាប័នពាក់ព័ន្ធ នៃរាជរដ្ឋាភិបាលកម្ពុជា សមាគម CWA បានសម្រេចបញ្ចូលសមាជិកបន្ថែមមានទាំងរូបវន្តបុគ្គល និងនិតិបុគ្គល។ ដូច្នេះហើយទើបក្រសួងមហាផ្ទៃបានចេញសេចក្តីប្រកាសលេខ ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគម CWA ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋានទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគ CWA មបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៦ សមាគម CWA មានសមាជិកសរុបចំនួន ៣៤០ ក្នុងនោះមានសមាជិកអាជីពចំនួន ២៨៦ ស្ថានីយ ដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣ រាជធានី/ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា និងសមាជិកគាំទ្រចំនួន ៥៤ ក្រុមហ៊ុន។

១.១. បច្ចុប្បន្នភាពសមាជិក

តារាងបច្ចុប្បន្នភាពសមាជិកគិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២៦៖



១.២. បច្ចុប្បន្នភាពអំពីសមាជិកសមាគម CWA

តារាងបច្ចុប្បន្នភាពអំពីសមាជិកគិតត្រឹមដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៦៖

ចំនួនសមាជិក	សមាជិកអាជីព	សមាជិកគាំទ្រ	សរុប
ចំនួនសមាជិកសរុបត្រឹមដំណាច់ត្រីមាសទី២ ឆ្នាំ២០២៦	២៨៥	៥៣	៣៣៨
ចំនួនសមាជិកថ្មី	១	១	២
ចំនួនសមាជិកសរុបត្រឹមត្រីមាសទី៣ ឆ្នាំ២០២៦	២៨៦	៥៤	៣៤០

២. ការងារស្នូលសមាគម CWA

២.១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ត្រីមាសទី២

ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៦ សមាគម CWA បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ត្រីមាសទី២ នៅការិយាល័យសមាគម CWA និងតាមប្រព័ន្ធអនឡាញ។ របៀបវារៈសម្រាប់កិច្ចប្រជុំរួមមាន៖

១. មតិស្វាគមន៍និងបើកកិច្ចប្រជុំ ដោយ **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាភិបាល

២. ពិនិត្យលើកំណត់ហេតុប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាល និងចុះហត្ថលេខា

៣. លទ្ធផលការងារត្រីមាសទី២ និងផែនការត្រីមាសទី៣ របស់សមាគម CWA

៤. ការរៀបចំកិច្ចប្រជុំថ្នាក់តំបន់លើកទី២ និងជំនួបសម្តែងការគួរសម នៅខេត្តបាត់ដំបង

៥. ការរៀបចំសន្និសីទ និងពិព័រណ៍ទឹកកម្ពុជាលើកទី៦

៦. ផ្សេងៗ (ការប្រមូលបញ្ហា និងសំណូមពរ) ពីសមាជិក



រូបភាពទី ១ ៖ កិច្ចប្រជុំក្រុមប្រឹក្សាកិបាលសម្រាប់ត្រីមាសទី២

២.២. កិច្ចប្រជុំវិសាមញ្ញតាមប្រព័ន្ធអនឡាញ (Zoom)

ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២៦ ក្រុមប្រឹក្សាកិបាល និងថ្នាក់ដឹកនាំ សមាគម CWA បានរៀបចំ កិច្ចប្រជុំវិសាមញ្ញតាមប្រព័ន្ធអនឡាញ (Zoom)។ កិច្ចប្រជុំនេះរៀបចំឡើង ដើម្បីស្តាប់ និងពិភាក្សាអំពីបញ្ហាប្រឈមរបស់ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ដូត ទូច (សំពៅលូន) ដែលជាសមាជិករបស់សមាគម CWA ព្រមទាំងផ្តល់យោបល់ និងធាតុចូល ដើម្បីគាំទ្រដល់ការពិចារណា និងការធ្វើសេចក្តីសម្រេចចិត្តរបស់ លោក ដូត ទូច។

សមាគម CWA ឈរជាមួយសមាជិករបស់ខ្លួនតាមរយៈការស្តាប់ ការចែករំលែកបទពិសោធន៍ និងការផ្តល់ការគាំទ្រក្នុងពេលមានបញ្ហាប្រឈម សមាគម CWA បន្តបំពេញតួនាទីជាដៃគូរបស់សមាជិក ក្នុងការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធភាព ជាក់ស្តែង និងនិរន្តរភាព។



រូបភាពទី ២៖ កិច្ចប្រជុំវិសាមញ្ញក្រុមប្រឹក្សាកិបាល តាមអនឡាញ

២.៣. កិច្ចប្រជុំថ្នាក់តំបន់

នៅក្នុងត្រីមាសទី៣ នេះសមាគម CWA បានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន ៣ លើក ក្រោមប្រធានបទ «ធ្វើការរួមគ្នាដើម្បីជំរុញសេវាផ្គត់ផ្គង់ទឹកស្អាតឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០(SDGs 2030)»

- **លើកទី១ ខេត្តបាត់ដំបង៖** ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៦ នៅសណ្ឋាគារ ស្ទឹងសង្កែ ខេត្តបាត់ដំបង មានអ្នកចូលរួមសរុបចំនួន ១០៩ នាក់ ក្នុងនោះស្រី ១១ នាក់ ដែលអញ្ជើញមកពី តំណាងក្រសួង ឧ.វ.ប.ន. តំណាងរដ្ឋបាលខេត្តបាត់ដំបង ពោធិ៍សាត់ និងកំពង់ឆ្នាំង តំណាងមន្ទីរ ឧ.វ.ប.ន. ខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងប៉ៃលិន ព្រមទាំងតំណាងមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីររ៉ែ និងថាមពល មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន តំណាងអង្គការ Water.org បុគ្គលិកសមាគម CWA និងតំណាងក្រុមហ៊ុនឧបត្ថម្ភ។ ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ៣២ នាក់ (ស្រី ៣ នាក់) តំណាងឱ្យ ២៩ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មកពីខេត្តបាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង និងខេត្តប៉ៃលិន។



រូបភាពទី ៣៖ កិច្ចប្រជុំថ្នាក់តំបន់ខេត្តបាត់ដំបង



រូបភាពទី ៤៖ មន្ទីរពាក់ព័ន្ធនានា ចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់ខេត្តបាត់ដំបង

- **លើកទី២ ខេត្តកំពត៖** ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៦ នៅសណ្ឋាគារ ភាព សុខុម ខេត្តកំពត មានអ្នកចូលរួមសរុបចំនួន ១៤៣ នាក់ (ស្រី ២៧ នាក់) ដែលអញ្ជើញមកពីតំណាងក្រសួង ឧ.វ.ប.ន. តំណាងរដ្ឋបាលខេត្តកណ្តាល តាកែវ កំពង់ស្ពឺ និងខេត្តកំពត តំណាងមន្ទីរ ឧ.វ.ប.ន. ខេត្តកោះកុង ព្រះសីហនុ កំពង់ស្ពឺ កណ្តាល តាកែវ និងខេត្តកណ្តាល តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីររ៉ែ និងថាមពល មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី តំណាងរដ្ឋាករទឹកកំពត ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន តំណាងអង្គការ Water.org បុគ្គលិកសមាគម CWA និងតំណាងក្រុមហ៊ុនឧបត្ថម្ភ។ ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ៥២ នាក់ (ស្រី ៩ នាក់) តំណាងឱ្យ ៤៤ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតមកពី ៦ ខេត្ត។



រូបភាពទី ៥៖ គណៈអធិបតី និងអ្នកចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់ខេត្តកំពត

- **លើកទី៣ ខេត្តកំពង់ចាម៖** ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២៦ នៅសណ្ឋាគារ ភ្នំប្រុស ខេត្តកំពង់ចាម មានអ្នកចូលរួមសរុប ១៦៣ នាក់ (ស្រី ២៩នាក់) ដែលអញ្ជើញមកពីតំណាង ឧ.វ.ប.ន. តំណាងរដ្ឋបាលខេត្តក្រចេះ ព្រៃវែង ត្បូងឃ្មុំ និងខេត្តកំពង់ចាម តំណាងមន្ទីរ ឧ.វ.ប.ន ខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ ត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង និងខេត្តកំពង់ចាម តំណាងមន្ទីរ ធនធានទឹក និងឧតុនិយម មន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តត្បូងឃ្មុំ ស្វាយរៀង ព្រៃវែង ក្រចេះ និងខេត្តកំពង់ចាម តំណាងមន្ទីររ៉ែ និងថាមពល មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី មន្ទីរបរិស្ថាន ខេត្តក្រចេះ ស្វាយរៀង ព្រៃវែង និងខេត្តកំពង់ចាម តំណាងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ប្រតិបបត្តិការនៅខេត្តត្បូងឃ្មុំ) តំណាងរដ្ឋាករទឹកស្វាយរៀង តំណាងរដ្ឋាករទឹកកំពង់ចាម ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បុគ្គលិកសមាគម CWA និងតំណាងក្រុមហ៊ុនឧបត្ថម្ភ។ ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ៧០ នាក់ (ស្រី ២៩ នាក់) តំណាងឱ្យ ៥៨ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត មកពី ៥ ខេត្ត។

កិច្ចប្រជុំនេះមានគោលបំណងស្តាប់មតិ និងបញ្ហាប្រឈមរបស់សមាជិក ស្វែងរកដំណោះស្រាយពង្រឹងកិច្ចសហការ និងចែករំលែកចំណេះដឹង បទពិសោធន៍ បច្ចុប្បន្នភាពច្បាប់ និងបទប្បញ្ញត្តិ ដំណោះស្រាយហិរញ្ញវត្ថុ និងបច្ចេកវិទ្យាថ្មីៗក្នុងវិស័យទឹកស្អាត។



រូបភាពទី ៦៖ គណៈអធិបតី និងអ្នកចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់ខេត្តកំពង់ចាម



រូបភាពទី ៧៖ ប្រតិបត្តិករ និងមន្ទីរពាក់ព័ន្ធចូលរួមក្នុងកិច្ចប្រជុំថ្នាក់តំបន់ខេត្តកំពង់ចាម

២.៤. កិច្ចគាំពារសមាជិក

ក្នុងត្រីមាសទី៣ នេះសមាគម CWA បានជួយសម្របសម្រួលដោះស្រាយបញ្ហា និងគាំទ្រសមាជិកដូចខាងក្រោម៖

ល.រ	ឈ្មោះស្ថានីយ	ខេត្ត
១	ស្ថានីយទឹកស្អាត ឃុំសែនជី	កំពង់ស្ពឺ
២	ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត	បាត់ដំបង
៣	ក្រុមហ៊ុនគីមមុិចខនស្ត្រាក់សិន អេនអិនវើសមេន(រោងចក្រផលិតទឹកស្អាត អ្នកលឿង)	ព្រៃវែង
៤	ស្ថានីយទឹកស្អាតដូត ទូច	បាត់ដំបង
៥	ស្ថានីយទឹកស្អាត ចង្ហា	បន្ទាយមានជ័យ
៦	ស្ថានីយទឹកស្អាត ពេជ្រ ចិន្តា	បាត់ដំបង

៧	ស្ថានីយទឹកស្អាត ម៉ារីន ពេជ្រសារ	តាកែវ
៨	ស្ថានីយទឹកស្អាត ត្រពាំងនៀល (ឈើទាលស្លោះ)	តាកែវ



រូបភាពទី ៨៖ កិច្ចប្រជុំសម្រុះសម្រួលវាងទឹកស្អាតខោប៊ុនហ៊ាត និងរដ្ឋាករទឹកបាត់ដំបង



រូបភាពទី ៩៖ កិច្ចប្រជុំសម្រុះសម្រួលស្ថានីយទឹកស្អាតឃុំសែនជី និងវិស្វកម្មស្ថាបនា

២.៥. ការចុះសួរសុខទុក្ខសមាជិក

ក្នុងត្រីមាសទី២ សមាគម CWA បានចុះសួរសុខទុក្ខសមាជិករបស់ខ្លួនដែលជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ឯកជនចំនួន ៩ ស្ថានីយ ក្នុងគោលបំណងដើម្បីពង្រឹងទំនាក់ទំនង ស្វែងយល់អំពីស្ថានភាពទូទៅរបស់សមាជិក បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយសមស្របជូនសមាជិក ព្រមទាំងផ្តល់អនុសាសន៍ណែនាំដល់សមាជិកក្នុងការកែលម្អ។

តារាងស្ថានីយដែលសមាគម CWA បានចុះសួរសុខទុក្ខ៖

ល.រ	ឈ្មោះស្ថានីយ	ខេត្ត
១	ស្ថានីយទឹកស្អាត ប៉ោ ចន្ថា	កំពង់ធំ
២	ស្ថានីយទឹកស្អាត ចង្ហា	បន្ទាយមានជ័យ
៣	ស្ថានីយទឹកស្អាត ដូតទូច	បាត់ដំបង
៤	ស្ថានីយទឹកស្អាត ពេជ្រចិន្តា	បាត់ដំបង
៥	ស្ថានីយទឹកស្អាត ខោ ប៊ុនហ៊ាត	បាត់ដំបង
៦	ស្ថានីយទឹកស្អាត បាធាយ	កំពង់ចាម







រូបភាពទី ១០៖ សកម្មភាពក្រុមការងារសមាគម CWA ចុះសួរសុខទុក្ខសមាជិក

២.៦. ការធ្វើតេស្តគុណភាពទឹកស្អាត និងជ្យាតេស្ត

នៅក្នុងត្រីមាសទី៣ នេះបុគ្គលិកបច្ចេកទេសសមាគម CWA បានការធ្វើតេស្តគុណភាពទឹកស្អាត និងធ្វើជ្យាតេស្តជូនសមាជិកដូចខាងក្រោម៖

ល.រ	ការតេស្តគុណភាពទឹកស្អាត
១	ស្ថានីយទឹកស្អាត ចំណា
២	ស្ថានីយទឹកស្អាត មេសាង
	ការធ្វើជ្យាតេស្ត
១	ស្ថានីយទឹកស្អាត ភ្នំលៀប
២	ស្ថានីយទឹកស្អាត ចំណា
៣	ស្ថានីយទឹកស្អាត ក្អមសំណ



រូបភាពទី ១១៖ សកម្មភាពបុគ្គលិកសមាគម CWA ធ្វើជ្យាតេស្តទឹកជូនសមាជិក

២.៧. វគ្គបណ្តុះបណ្តាល

ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៦ សមាគម CWA បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«ការគ្រប់គ្រងឯកសារ និងប្រព័ន្ធគ្រប់គ្រងឯកសារសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» ក្រោមអធិបតីភាព **ឧកញ៉ា លឹម មិញ្ញ** នាយកប្រតិបត្តិ សមាគម CWA នៅសណ្ឋាគារ សាន់វ៉េ ភ្នំពេញ។ វគ្គបណ្តុះបណ្តាលនេះ មានការចូលរួមពីប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ឯកជន ចំនួន ៤៨ នាក់(ស្រី ២០ នាក់) មកពី ៤២ ស្ថានីយ។

វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំឡើងក្នុងគោលបំណង ពង្រឹងសមត្ថភាពម្ចាស់ និងបុគ្គលិកស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្នុងការរៀបចំ គ្រប់គ្រង រក្សាទុក និងប្រើប្រាស់ឯកសារប្រកបដោយប្រសិទ្ធភាព ស្របតាមតម្រូវការបច្ចេកទេស ច្បាប់ និងការគ្រប់គ្រងអាជីវកម្ម។



រូបភាពទី ១២៖ សកម្មភាពកិច្ចពិភាក្សាក្នុងវគ្គបណ្តុះបណ្តាល

២.៧. កិច្ចសន្ទនាប្រចាំខែអំពីវិស័យទឹកស្អាត

នៅក្នុងត្រីមាសទី៣ នេះសមាគម CWA បានរៀបចំកិច្ចសន្ទនាប្រចាំខែអំពី វិស័យទឹកស្អាតបានចំនួន ២ លើក តាមប្រពន្ធ័អនឡាញ និងផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុករបស់សមាគម CWA ។ កិច្ចសន្ទនាប្រចាំខែរួមមាន៖





២.៨. ការជួបសម្តែងការគួរសម

នៅក្នុងត្រីមាសទី៣ នេះថ្នាក់ដឹកនាំសមាគម CWA និងសហការីបានចូលជួបសម្តែងការគួរសម ចំនួន ៣ លើក ក្នុងគោលបំណងបង្ហាញពីការងាររបស់ CWA ការផ្គត់ផ្គង់ទឹកស្អាត និងបញ្ហាប្រឈមរបស់ប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាត ដើម្បីទទួលបានការគាំទ្រ និងកសាងទំនាក់ទំនងល្អពីរដ្ឋបាលខេត្ត និងមន្ទីរពាក់ព័ន្ធ។

- ✓ **ខេត្តបាត់ដំបង៖** ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៦ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយរដ្ឋបាលខេត្តបាត់ដំបង ដែលដឹកនាំដោយ **ឯកឧត្តម ឆាយ ម៉ាទីណាល់** អភិបាលរង និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ លូ** អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង និងមានការចូលរួមពីលោកប្រធាន អនុប្រធាន និងមន្ត្រីមន្ទីរពាក់ព័ន្ធរួមមាន៖ មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីររ៉ែ និងថាមពល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី។




រូបភាពទី ១៣៖ ការជួបសម្តែងការគួរសមជាមួយរដ្ឋបាលខេត្តបាត់ដំបង

- ✓ **ខេត្តកំពត៖** ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពត ដែលដឹកនាំដោយ **ឯកឧត្តម អ៊ឹង ឆាយ** អភិបាលរង និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត។



រូបភាពទី ១៤៖ ការជួបសម្តែងការគួរសមជាមួយរដ្ឋបាលខេត្តកំពត

- ✓ **ខេត្តកំពង់ចាម៖** ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៦ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពង់ចាមដែលដឹកនាំដោយ **ឯកឧត្តម ឡោ ចាន់លី** អភិបាលរង និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម។




រូបភាពទី ១៥៖ ការជួបសម្តែងការគួរសមជាមួយរដ្ឋបាលខេត្តកំពង់ចាម

៣. កិច្ចសហប្រតិបត្តិការ

ខេត្តកំពត៖ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៦ សមាគម CWA សហការជាមួយមន្ទីរ ឧ.វ.ប.ន. ខេត្តកំពត រៀបចំកិច្ចប្រជុំជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅក្នុងខេត្តកំពត ដែលមិនទាន់ចូលជាសមាជិកសមាគម។ កិច្ចប្រជុំដឹកនាំដោយ **លោក ខេង សារិន** អនុប្រធានមន្ទីរ ឧ.វ.ប.ន. ខេត្តកំពត **លោក ឡេង ខៀវ** ប្រធានក្រុមប្រឹក្សាកិបាលសមាគម CWA និង **លោក លឹម មិញ** នាយកប្រតិបត្តិសមាគម CWA។

កិច្ចប្រជុំមានគោលបំណង បង្កើនសមាជិកភាពរបស់សមាគម CWA តាមរយៈការណែនាំអំពីសមាគម CWA តួនាទី និងភារកិច្ច ព្រមទាំងបង្ហាញពីអត្ថប្រយោជន៍នៃការចូលជាសមាជិកសមាគម CWA។ ជាមួយគ្នានេះ កិច្ចប្រជុំក៏មានគោលបំណងពង្រឹងកិច្ចសហការរវាងសមាគម CWA ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងមន្ទីរ ឧ.វ.ប.ន. ខេត្តកំពត ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងខេត្តកំពតឱ្យកាន់តែមានប្រសិទ្ធភាព និងចីរភាព។



រូបភាពទី ១៦៖ កិច្ចប្រជុំជាមួយប្រតិបត្តិករមិនមែនជាសមាជិកនៅខេត្តកំពត

ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦ សមាគម CWA បានទទួលជួបប្រជុំជាមួយក្រុមការងារ JICA ដែលដឹកនាំដោយលោក **MATSUMOTO SHIGENYUKI**, Ph.D. Global Environment Department Senior Deputy Director General ដើម្បីពិភាក្សាលើគម្រោងថ្មីឈ្មោះ «គម្រោងសហការបច្ចេកទេសថ្មីសម្រាប់វិស័យទឹកស្អាត»។



រូបភាពទី ១៧៖ កិច្ចប្រជុំជាមួយក្រុមការងាររបស់អង្គការ JICA នៅការិយាល័យសមាគម CWA

ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៦ សមាគម CWA បានជួបពិភាក្សាជាមួយ Water Solutions South-East Asia (WSS) ដើម្បីពិភាក្សាអំពីឱកាសនៃការបង្កើតបណ្តាញទំនាក់ទំនង ការចែករំលែកចំណេះដឹង និងកិច្ចសហការនាពេលអនាគតរវាង សមាគម CWA និង WSS ក្នុងវិស័យទឹកស្អាត។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការពិភាក្សាដ៏មានតម្លៃ និងសង្ឃឹមថា នឹងបន្តពង្រឹងភាពជាដៃគូ និងស្វែងរកឱកាសថ្មីៗសម្រាប់កិច្ចសហការរួមគ្នា ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យទឹកស្អាតប្រកបដោយចីរភាព។



រូបភាពទី ១៨៖ ជំនួបពិភាក្សារវាងសមាគម CWA និងក្រុមហ៊ុន Water Solutions South-East Asia

៤. ទៀតណាម Water Week

ថ្ងៃទី១៥-១៦ ខែកញ្ញា ឆ្នាំ២០២៦ ប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ នៃសមាគម CWA បានចូលរួមកម្មវិធី Vietnam Water Week 2026 នៅទីក្រុងហាណូយ ដើម្បីរៀនសូត្រពីបទពិសោធន៍ល្អៗដើម្បីផ្លាស់ប្តូរចំណេះដឹង និងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យទឹកស្អាត។



រូបភាពទី ១៩៖ Vietnam Water Week នៅទីក្រុងហាណូយ

ទន្ទឹមគ្នានេះដែរប្រធានក្រុមប្រឹក្សាភិបាល និងនាយកប្រតិបត្តិ សមាគម CWA ក៏បានចូលរួមកិច្ចប្រជុំតុមូល SEAWUN 2026 នៅទីក្រុងហាណូយ ជាមួយតំណាងសមាគម និងស្ថាប័នផ្គត់ផ្គង់ទឹកក្នុងតំបន់អាស៊ីអាគ្នេយ៍ ព្រមទាំងសមាគមទឹកអូស្ត្រាលី (AWA) ដែលផ្តោតលើការចែករំលែកចំណេះដឹង និងបទពិសោធន៍ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងការផ្លាស់ប្តូរបទពិសោធន៍វិជ្ជាជីវៈ ព្រមទាំងពិភាក្សាអំពីផែនការសកម្មភាពរួមរបស់ SEAWUN ឆ្នាំ ២០២៦–២០២៨ និងកិច្ចសហការគាំទ្រ IWA World Water Congress & Exhibition 2028 នៅប្រទេសម៉ាឡេស៊ី។



រូបភាពទី ២០៖ កិច្ចប្រជុំគុមួល SEAWUN 2026 នៅទីក្រុងហាណូយ

៣. ការងារគម្រោង

៣.១ គម្រោង«ការបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតតាមបំពង់សម្រាប់គ្រួសារដែលមិនទាន់បានប្រើប្រាស់ទឹកស្អាត» គាំទ្រដោយអង្គការ Water.org

៣.១.១ ការជ្រើសរើសសមាជិកគម្រោងបន្ថែម

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៦ នេះ គម្រោងបានជ្រើសរើសសមាជិកបន្ថែមចំនួន ១ ស្ថានីយ។ សមាជិកគម្រោងសរុបគឺ ៧៥ ស្ថានីយ។

ល.រ	ឈ្មោះស្ថានីយ	ឈ្មោះប្រតិបត្តិករ	ទីតាំង
១	ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចង្ហា	លោកស្រី ស ស្រីនាង	ខេត្តបន្ទាយមានជ័យ

៣.១.២ ការកសាងសមត្ថភាព

ក. សិក្ខាសាលាស្តីពី«ការឆ្លុះបញ្ចាំង និងការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំរបស់ក្រុមអធិការកិច្ច»

ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៦ សមាគម CWA បានសហការជាមួយក្រសួង ឧ.វ.ប.ន. រៀបចំសិក្ខាសាលាស្តីពី**«ការឆ្លុះបញ្ចាំង និងការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំរបស់ក្រុមអធិការកិច្ច»** ក្រោមការឧបត្ថម្ភពីអង្គការ Water.org។

សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន. ជាប្រធានគណៈអធិបតី **លោក លឹម មិញ្ញ** នាយកប្រតិបត្តិសមាគម CWA និង**លោកស្រី អេយ សត្យា** អ្នកដឹកនាំផលប័ត្រនៃអង្គការ Water.org។

គោលបំណងនៃសិក្ខាសាលា៖

១. កំណត់ចំណុចដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនត្រូវកែលម្អ ដោយផ្អែកលើលទ្ធផលក្នុងរបាយការណ៍។
២. ពិភាក្សាអំពីវិធីសាស្ត្រ និងផែនការដែលប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននឹងអនុវត្ត ដើម្បីកែលម្អ ដោយផ្អែកលើលទ្ធផល និងអនុសាសន៍ក្នុងរបាយការណ៍។
៣. ពិភាក្សាអំពីការគាំទ្ររបស់ក្រសួង ឧ.វ.ប.ន. និង/ឬសមាគម CWA ដៃគូអភិវឌ្ឍន៍ក្នុងការជួយប្រតិបត្តិករ

ផ្គត់ផ្គង់ទឹកស្អាតឯកជនអនុវត្តសកម្មភាពកែលម្អទាំងនោះ។

សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីក្រសួង ឧ.វ.ប.ន. ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អង្គការ Water.org និងសមាគម CWA សរុបចំនួន ៧០ នាក់ (ស្រី ១៤ នាក់) ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន ៥៤ ស្ថានីយ។



រូបភាពទី ២១៖ ការឆ្លុះបញ្ចាំង និងការឆ្លើយតបទៅនឹងអនុសាសន៍ណែនាំរបស់ក្រុមអធិការកិច្ច

ខ. សិក្ខាសាលាស្តីពី«ការឆ្លុះបញ្ចាំងពីការរៀបចំ និងការអនុវត្តផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០»

ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៦ សមាគម CWA បានរៀបចំសិក្ខាសាលាស្តីពី**«ការឆ្លុះបញ្ចាំងពីការរៀបចំ និងការអនុវត្តផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០»** ក្រោមការឧបត្ថម្ភពីអង្គការ Water.org។ សិក្ខាសាលានេះប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោក លឹម មិញ** នាយកប្រតិបត្តិសមាគម CWA និង **លោក ឥន ង៉ាន់ឡែ** អ្នកគ្រប់គ្រងកាពជាដៃគូនៃអង្គការ Water.org។

គោលបំណងនៃសិក្ខាសាលា៖

១. ឆ្លុះបញ្ចាំង និងវាយតម្លៃលទ្ធផលនៃការរៀបចំ និងការអនុវត្តផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ ២០២៦–២០៣០ ដែលបានរៀបចំ និងដាក់ជូនក្រសួង ឧ.វ.ប.ន.។
២. ពិនិត្យ និងពិភាក្សាអំពីចំណុចខ្លាំង បញ្ហាប្រឈម និងមេរៀនដែលទទួលបានពីដំណើរការរៀបចំ និងការអនុវត្តផែនការវិនិយោគ។
៣. ប្រមូលមតិយោបល់ និងអនុសាសន៍ពីប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងភាគីពាក់ព័ន្ធ ដើម្បីកែលម្អដំណើរការរៀបចំ និងការអនុវត្តផែនការវិនិយោគនាពេលខាងមុខ។

សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីបុគ្គលិកអង្គការ Water.org បុគ្គលិកសមាគម CWA និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន សរុបចំនួន ៦០ នាក់ (ស្រី ១០ នាក់) ក្នុងនោះមានប្រតិបត្តិករចំនួន ចំនួន ៥៣ មកពី ៤៩ ស្ថានីយ។



រូបភាពទី ២២៖ ការឆ្លុះបញ្ចាំងពីការរៀបចំ និងការអនុវត្តផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០

ខ. ការចុះបង្ហឹក

ក្នុងត្រីមាសនេះ បុគ្គលិកបច្ចេកទេសសមាគម CWA បានផ្តល់ការបង្ហឹកលើបច្ចេកទេសនៃការវិភាគគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ និងធ្វើជ្រាវតេស្តគុណភាពទឹកឆៅ ព្រមទាំងបានសិក្សាពីស្ថានភាពប្រភពទឹករហូតដល់ស្តានីយចែកចាយទឹកស្អាត ជូនដល់អ្នកគ្រប់គ្រង និងបុគ្គលិក ចំនួន ៥ ស្តានីយ៖

ល.រ	ឈ្មោះស្ថានីយ	កាលបរិច្ឆេទ	ខេត្ត
១	ស្តានីយផ្គត់ផ្គង់ទឹកស្អាតត្រពាំងនាល (ឈើទាលស្លោះ)	០៣.កក្កដា.២០២៦	តាកែវ
២	ស្តានីយផ្គត់ផ្គង់ទឹកស្អាតស្រុកបុរីដែលសារ	២៣.កក្កដា.២០២៦	
៣	ស្តានីយផ្គត់ផ្គង់ទឹកស្អាតថ្នល់បំបែកសន្លុង	២៤.កក្កដា.២០២៦	
៤	ស្តានីយផ្គត់ផ្គង់ទឹកស្អាត សុត សឿន	២៥.សីហា.២០២៦	ពោធិ៍សាត់
៥	ស្តានីយផ្គត់ផ្គង់ទឹកស្អាត ក្រវ៉ា	០៣.កញ្ញា.២០២៦	កំពង់ធំ



រូបភាពទី ២៣៖ សកម្មភាពបង្ហឹកអំពីការធ្វើតេស្តទឹកស្អាត និងជ្រាវតេស្ត

៣.១.៣ ការគាំទ្រដល់សមាជិកគម្រោង

ក. ការប្រមូលលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃ ៥ប៉ារ៉ាម៉ែត្រ និងការផ្តល់អនុសាសន៍

សមាគម CWA បានប្រមូលលទ្ធផលតេស្តគុណភាពទឹកស្អាតប្រចាំថ្ងៃរៀងរាល់ខែពីសមាជិក ជាលទ្ធផល ៥៨/៧៥ ស្ថានីយ បានផ្ញើលទ្ធផលតេស្តមកសមាគម CWA ជាទៀងទាត់រៀងរាល់ខែ។ អ្នកបច្ចេកទេសសមាគម CWA បានផ្តល់ការណែនាំដល់ប្រតិបត្តិករក្នុងករណីលទ្ធផលមិនអនុលោមតាមស្តង់ដារទឹកស្អាតថ្នាក់ជាតិ។

ចំពោះស្ថានីយចំនួន ១៧ ស្ថានីយ ដែលមិនបានផ្ញើលទ្ធផលមកដោយសារមូលហេតុ ១) ទិញទឹកដុំពីប្រតិបត្តិការទឹកស្អាតជិតខាង និងពឹងផ្អែកលើប្រភពផ្គត់ផ្គង់នោះ ២) ខូចឧបករណ៍សម្រាប់ធ្វើតេស្តគុណភាពទឹកស្អាត និងកំពុងជួសជុល ៣) មិនមានឧបករណ៍ ៤) ប្រើប្រាស់ប្រព័ន្ធធ្វើតេស្តតាមអនឡាញ ប៉ុន្តែមិនអាចទាញយកលទ្ធផលតេស្តគុណភាពទឹកស្អាតពីប្រព័ន្ធបាន និង ៥) មិនបានផ្ញើលទ្ធផលតេស្តគុណភាពទឹកស្អាតដែលតម្រូវឱ្យក្រុមការងារជំរុញ និងតាមដានបន្ថែម។

ខ. ការគាំទ្រលើការតាមដានទឹកគ្មានចំណូល

សមាគម CWA បានប្រមូលលទ្ធផលតាមដានទឹកគ្មានចំណូលពីសមាជិកគម្រោងចំនួន ៧៥ ស្ថានីយ។ ខាងក្រោមជាលទ្ធផលដែលសម្រេចបាន៖

ល.រ	លទ្ធផល	ខែកក្កដា	ខែសីហា	ខែកញ្ញា
១	កម្រិត ល្អ / ប្រសិទ្ធភាព (NRW < 20%)	២២ ស្ថានីយ	២២ ស្ថានីយ	២៤ ស្ថានីយ
២	កម្រិត មធ្យម / អាចទទួលយកបាន (NRW 20%–30%)	៩ ស្ថានីយ	១០ ស្ថានីយ	៩ ស្ថានីយ
៣	កម្រិត ទាប / ការបាត់បង់ខ្ពស់ (NRW> 30%)	៥ ស្ថានីយ	៧ ស្ថានីយ	១០ ស្ថានីយ
សរុប		**៣៦ ស្ថានីយ**	**៣៩ ស្ថានីយ**	**៤៣ ស្ថានីយ**

យោងតាមលទ្ធផលខាងលើ អ្នកបច្ចេកទេសរបស់សមាគម CWA បានផ្តល់ការណែនាំដល់ប្រតិបត្តិករ ដើម្បីពិនិត្យ មើលការគ្រប់គ្រងទឹកគ្មានចំណូលជូនសមាជិកផងដែរ ។

ចំពោះប្រតិបត្តិករចំនួនដែលមិនបានផ្ញើលទ្ធផលមកដោយសារមូលហេតុ ១) គ្មាននាឡិកាមេ ២) គ្មាននាឡិកាមេគ្រប់គ្រាន់ ៣) នាឡិកាមេខូចមិនដំណើរការ ៤) កត់ត្រាទិន្នន័យមិនត្រឹមត្រូវ និង ៥) មិនបានធ្វើលទ្ធផលតាមដានទឹកគ្មានចំណូល ដែលតម្រូវឱ្យក្រុមការងារជំរុញ និងតាមដានបន្ថែម។

គ. ការផ្តល់សេវាគូរផែនទីបណ្តាញ និងការរៀបចំផែនការវិនិយោគរយៈពេលមធ្យម

សមាគម CWA បានផ្តល់សេវាកម្មជូនសមាជិក ដោយមានការចូលរួមបជិភាគពីអង្គការ Water.org សមាគម CWA និងប្រតិបត្តិករ៖

ល.រ	សេវាកម្ម	ចំនួនប្រតិបត្តិករ
១	គូរផែនទីបណ្តាញបំពង់ទឹកស្អាត	២ ស្ថានីយ
២	រៀបចំផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០	២ ស្ថានីយ
៣	គូរផែនទីបណ្តាញបំពង់ទឹកស្អាត និងផែនការវិនិយោគរយៈពេលមធ្យមសម្រាប់ឆ្នាំ២០២៦-២០៣០	៧ ស្ថានីយ
	សរុប	**១១ ស្ថានីយ**



រូបភាពទី ២៤៖ បុគ្គលិកសមាគម CWA ចុះផ្តល់សេវាកម្មជូនសមាជិក

៣.១.៤ ពង្រឹងអភិបាលកិច្ច និងប្រសិទ្ធភាពប្រតិបត្តិការរបស់សមាជិកជាប្រតិបត្តិករ

ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៦ សមាគ CWA មបានសហការជាមួយក្រសួង ឧ.វ.ប.ន. ក្រសួងមហាផ្ទៃ រដ្ឋបាលខេត្តកំពង់ធំ សម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អង្គការ និងដៃគូពាក់ព័ន្ធនានាស្តីពី **«រួមគ្នាបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាត»** បានចំនួនមួយប្រជុំ ក្រោមការឧបត្ថម្ភពីអង្គការ Water.org។ គោលបំណងសំខាន់ៗនៃកិច្ចប្រជុំ រួមមាន៖

១. ផ្សព្វផ្សាយលិខិតណែនាំលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ របស់ក្រសួងមហាផ្ទៃ ស្តីពី**«ការជំរុញលើកកម្ពស់ និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ»** ឱ្យកាន់តែមានប្រសិទ្ធភាព។

២. កំណត់បញ្ហាប្រឈមចម្បងៗ ស្វែងរកដំណោះស្រាយ និងរួមគ្នាក្នុងការធានាឱ្យមានភាពប្រសើរក្នុងការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋ។

៣. បង្កើនទំនាក់ទំនង និងកិច្ចសហការរវាងក្រសួង មន្ទីរ រដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការដៃគូ និងភាគីពាក់ព័ន្ធក្នុងវិស័យ ដើម្បីស្វែងរកការគាំទ្រក្នុងការឆ្លើយតបជាវិជ្ជមានទៅនឹងតម្រូវការរបស់ប្រជាជន។

៤. បង្កើនចំណេះដឹងបន្ថែមអំពីវិស័យផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ ជាពិសេសច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត។


កិច្ចប្រជុំពិគ្រោះយោបល់៖

កិច្ចប្រជុំនេះប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ជា ឌៀង** អនុរដ្ឋលេខាធិការ ក្រសួង ឧ.វ.ប.ន. **ឯកឧត្តម សួន តារា** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ **ឯកឧត្តម ចួន រាសី** អភិបាលរងខេត្តកំពង់ធំ **លោក លឹម មិញ** នាយកប្រតិបត្តិសមាគម CWA និង **លោកស្រី អយ សត្យា** អ្នកដឹកនាំផលបត្រ នៃអង្គការ Water.org។

កិច្ចប្រជុំបានផ្តោតលើការជំរុញការអនុវត្ត លិខិតលេខ ៣៣១១ សជណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ ស្តីពីការជំរុញ និងបង្កើនលទ្ធភាពទទួលបានសេវាទឹកស្អាតនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពិភាក្សាអំពី

បញ្ហាប្រឈម ស្វែងរកដំណោះស្រាយ និងពង្រឹងកិច្ចសហការរវាងភាគីពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការផ្តល់សេវាទឹកស្អាតជូនប្រជាពលរដ្ឋ។

កិច្ចប្រជុំនេះមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរជំនាញ រដ្ឋាករទឹកសាធារណៈ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន អង្គការ និងដៃគូពាក់ព័ន្ធ សរុប ៧១ នាក់ (ស្រី ៨ នាក់) ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ១៦ នាក់ មកពី ១៦ ស្ថានីយ។



រូបភាពទី ២៥៖ កិច្ចប្រជុំពិគ្រោះយោបល់នៅខេត្តកំពង់ធំ

៣.១.៥ ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

ក. ការសម្របសម្រួលកម្ចី

ក្រុមការងារសមាគម CWA បានសម្របសម្រួល និងតាមដានសមាជិកចំនួន ១៦ ស្ថានីយ ក្នុងការស្នើប្រាក់កម្ចីពីស្ថាប័នហិរញ្ញវត្ថុ និងការទម្លាក់កម្ចីដើម្បីអភិវឌ្ឍអាជីវកម្ម។ ជាលទ្ធផល ៧ ស្ថានីយ ទទួលបានប្រាក់កម្ចីពីធនាគារ ១.៦៧៣.២៩២ ដុល្លារអាមេរិក (៣២០.០០០ ដុល្លារអាមេរិក ប្រើប្រាស់ដើម្បីសងត្រលប់កម្ចី និង ១.៣៥៣.២៩២ ដុល្លារអាមេរិក ប្រើប្រាស់សម្រាប់អភិវឌ្ឍអាជីវកម្មទឹកស្អាត។ ស្ថានីយទាំង ៧ ខាងលើមានកំណើនតំណអតិថិជនថ្មីចំនួន ៤.០២៧ ស្មើនឹងប្រជាជនចំនួន ១៩.៧៣២ នាក់ ទទួលបានសេវាទឹកស្អាតប្រើប្រាស់។

៣.១.៦ ការគាំទ្រសកម្មភាពស្នូលរបស់សមាគម CWA

នៅក្នុងត្រីមាសទី៣ គម្រោងបានគាំទ្រកិច្ចប្រជុំថ្នាក់តំបន់លើកចំនួន ៣ លើក ដែលប្រារព្ធនៅខេត្តបាត់ដំបង ខេត្តកំពត និងខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុបចំនួន ៤១៥ នាក់ (ស្រី ៤១នាក់) ក្នុងនោះមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំនួន ១៥៤ នាក់ តំណាងឲ្យ ១៣១ ស្ថានីយ។

៣.២ គម្រោងគាំទ្រដោយកម្មវិធី CAPRED

៣.២.១ គម្រោង«ការលើកកម្ពស់អ្នកអាជីពវ័យក្មេងសម្រាប់សេវាកម្មទឹកស្អាតដែលមានភាពធន់»

- រយៈពេលអនុវត្តគម្រោង៖ ចាប់ពីខែមិថុនា ឆ្នាំ២០២៦ ដល់ ខែមិថុនា ឆ្នាំ២០២៧
- ក្រុមគោលដៅ៖ វិស្វករវ័យក្មេងចំនួន ១៥ នាក់ និងប្រតិបត្តិករ ១៥ ស្ថានីយ/ក្រុមហ៊ុន

- ❖ បុគ្គលិកគម្រោង៖ ចំនួន ២ នាក់
- ❖ ស្ថានភាព៖ សមាគម CWA បានចុះកិច្ចព្រមព្រៀងជាមួយកម្មវិធី CAPRED នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២៦។
- ❖ លទ្ធផលក្នុងត្រីមាសទី៣៖ បានជ្រើសរើស កម្មសិក្សាការីចំនួន ១៥ នាក់ និងជ្រើសរើសប្រតិបត្តិករ ១៥ ស្ថានីយ/ក្រុមហ៊ុន។ បច្ចុប្បន្ននេះបាននិងកំពុងធ្វើការវាយតម្លៃ សុវត្ថិភាព និងការបង្កាការរំលោភបំពាន កេងប្រវ័ញ្ច និងបៀតបៀនផ្លូវភេទ នៅប្រតិបត្តិករ និងក្រុមហ៊ុនទាំង១៥។ កំពុងជ្រើសរើសបុគ្គលិក ដើម្បីអនុវត្តន៍គម្រោង

៣.២.២ គម្រោង«ការពិភាក្សាអំពីគោលនយោបាយនៅថ្នាក់ខេត្ត ដើម្បីទទួលបានលទ្ធផល»

- ❖ រយៈពេលអនុវត្តគម្រោង៖ ចាប់ពីខែមិថុនា ឆ្នាំ២០២៦ ដល់ ខែមិថុនា ឆ្នាំ២០២៧
- ❖ ខេត្តគោលដៅ៖ ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ
- ❖ បុគ្គលិកគម្រោង៖ ចំនួន ២ នាក់
- ❖ ស្ថានភាព៖ សមាគម CWA បានចុះកិច្ចព្រមព្រៀងជាមួយកម្មវិធី CAPRED នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០២៦។
- ❖ លទ្ធផលក្នុងត្រីមាសទី៣៖ កំពុងជ្រើរើសបុគ្គលិកដើម្បីអនុវត្តន៍គម្រោង

៣.៣ គម្រោង«លើកកម្ពស់សេវាផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា» គាំទ្រដោយអង្គការ WaterAid

- ❖ **រយៈពេលអនុវត្តគម្រោង៖** ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៦ ដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០៣០
- ❖ **ក្រុមគោលដៅ៖** ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតជាសមាជិកនៅខេត្តកំពង់ឆ្នាំង និងខេត្តកណ្តាល
- ❖ **ស្ថានភាព៖** សមាគម CWA បានចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយអង្គការ WaterAid នៅថ្ងៃទី១ ខែ កញ្ញា ឆ្នាំ២០២៦។